ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

# របាយការណ៍រីកចំរើន

## ប្រចាំឆ្នាំ២០១៤






រៀបចំដោយ:

ក្រុមការងារសុវត្ថិភាព ប.ដ.ជ នៃលេខាធិដ្ឋាន គ.ជ.អ.ប

ខែធ្នូ ឆ្នាំ២០១៤

**មាតិកា** **ទំព័រ**


**១.សេចក្តីផ្តើម**......................................................................................................១

**២.សកម្មភាព និងលទ្ធផលសម្រេចបាន**..........................................................................២

២.១.ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាព........២

២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤.......................៣

២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃឆ្នាំ២០១៣... ..................៤

២.៤.ការពង្រឹងសមត្ថភាព..............................................................................................៤

២.៥.ការគាំទ្រ និងកិច្ចសហការ.........................................................................................៦

**៣.បញ្ហាប្រឈមនានា**.....................................................................................................៦

**៤.ការសន្និដ្ឋាន**.........................................................................................................៧

**៥.សំណូមពរ និងអនុសាសន៍**...........................................................................................៨

**៦.សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៥**...............................................................................៨

**៧.ឧបសម្ព័ន្ធ៖**

៧.១. បញ្ជីសង្ខេបគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី

៧.២. តារាងតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤

៧.៣. បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពទាំងបីឆ្នាំ២០១៤

៧.៤. រូបថតសកម្មភាពក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

# ១. សេចក្តីផ្តើម

នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(ភីម) កិច្ចការពារសុវត្ថិភាព គឺជាឧបករណ៍សម្រាប់ការពារ**បរិស្ថាន សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងសិទ្ធិរបស់ជនជាតិដើមភាគតិច** ដែលអាចរងនូវផលប៉ះពាល់ដោយសារការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពទាំងនេះ គឺការជៀសវាងឬកាត់បន្ថយជាអប្បបរមាឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានឬចំណាយសង្គមចំពោះភាគីទីពាឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះ ដែលអាចទទួលរងឥទ្ធិពលពីគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។លេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាអាទិភាពសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់។ ទោះបី រាជរដ្ឋាភិបាលកម្ពុជា ពុំបានទទួលជំនួយពីធនាគារពិភពលោកដើម្បីគាំទ្រដល់ការអនុវត្តគម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានយ៉ាងណាក៏ដោយ។

គោលការណ៍ណែនាំអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថានគឺជាផ្នែកមួយយ៉ាងសំខាន់ដែលមានចែងក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់(ភីម) និងចាប់ផ្តើមតាំងពីមានការត្រួតពិនិត្យការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបី(បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច) ឱ្យស្របតាមគោលការណ៍ណែនាំដែលបានយល់ព្រមដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងម្ចាស់ជំនួយ។ លេខាធិការដ្ឋាន គ.ជ.អ.ប បានបង្កើតក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លីនិងជនជាតិដើមភាគតិច កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ទៅលើៈ ១)-ដំណើរការសិក្សានៃផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច និង២)-របាយការណ៍វិភាគផលប៉ះពាល់បរិស្ថានការរៀបចំសិក្សាដីធ្លី និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ព្រមទាំងការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពឱ្យមានប្រសិទ្ធភាព។

នៅឆ្នាំ២០១៤ ក្រុមការងារបានអនុវត្តតាមផែនការសកម្មភាព និងសម្រេចបានលទ្ធផលមួយចំនួន ដូចជាៈ ការប្រជុំប្រចាំឆមាសគួបផ្សំនិងការបើកវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញដល់នាយកឬនាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្តពីដំណើរការ និងគោលការណ៍នៃការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបី ព្រមទាំងបានចែករំលែកមេរៀន និងបទពិសោធន៍ល្អៗ ដល់អ្នកពាក់ព័ន្ធនានាផងដែរ។ ការពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍បរិស្ថាន និងជនជាតិដើមភាគតិច ព្រមទាំងការចុះពង្រឹងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចជាក់ស្តែងនៅតាមបណ្តាឃុំ សង្កាត់ និងទីតាំងគម្រោង ដោយបានជួបជាមួយមន្ត្រីពាក់ព័ន្ធ ដូចជា ទីប្រឹក្សាខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ លើសពីនេះ ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ និង បានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៤ជារៀងរាល់ខែដែលត្រូវការសិក្សាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ។ ជាមួយគ្នានេះដែរ ក្រុមការងារបានជួយពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសារ និងរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន របាយការណ៍វិធានការការពារជនជាតិដើមភាគតិច តាមគោលការណ៍ណែនាំក្នុងសៀវភៅ ភីម និងតាមបទដ្ឋាននានា មុននឹងដេញថ្លៃគម្រោង។

ក្រុមការងារបានចូលរួមពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅគោលការណ៍ណែនាំស្តីពីគម្រោង ក្រុង ស្រុក រាជធានី ខេត្ត និងការចូលរួមបង្ហាត់បង្ហាញក្នុងវគ្គបណ្តុះបណ្តាលសៀវភៅគោលការណ៍ណែនាំដល់មន្ត្រីនិងទីប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

### ២.១. ការត្រួតពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលត្រូវការសិក្សាសុវត្ថិភាព ៖

គម្រោងមូលនិធិឃុំ សង្កាត់ ដែលត្រូវបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៤ មានចំនួនសរុប**១៦៦៥** គម្រោងនៃចំនួន**១៥៣៧**ឃុំ សង្កាត់ ក្នុងនោះរួមមាន តម្រូវការសិក្សាបរិស្ថានសរុបចំនួន**៦៧៥**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**៦៤៨**គម្រោង និងតម្រូវការសិក្សាកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន**៩៨** គម្រោង។ គម្រោងមូលនិធិឃុំសង្កាត់ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប**៥៧៤** គម្រោង និងគម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីជនជាតិដើមភាគតិចមានចំនួនសរុប**៩៨**គម្រោង ដែលទីចាត់ការផែនការ និងវិនិយោគខេត្ត ផ្ញើរបាយការណ៍ទាំងនោះមកទីប្រឹក្សានិងមន្ត្រីកិច្ចការពារសុវត្ថិភាព ដើម្បី ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសពីភាពត្រឹមត្រូវមុននឹងអនុញ្ញាតឱ្យដំណើរការដេញថ្លៃគម្រោង ។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលត្រូវបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៣ ។

**រូបភាពទី១៖ ក្រាហ្វិចបង្ហាញពីចំនួនឃុំសង្កាត់ និងចំនួនគម្រោងឃុំសង្កាត់ដែលតម្រូវការសិក្សាសុវត្ថិភាព**




នៅក្នុងគម្រោងសរុបចំនួន**១៦៦៥**នេះ មានផ្លូវគ្រប់ប្រភេទចំនួន**១៣៨៣**ខ្សែ ស្ពានចំនួន**៣៥**កន្លែង ប្រព័ន្ធធារាសាស្ត្រមានដូចជាប្រឡាយ និងទំនប់ចំនួន**១៤៧**កន្លែង អណ្តូងស្នប់ និងស្រះជីកចំនួន**២០**កន្លែង សាលារៀនចំនួន**១៤**កន្លែង និង ផ្សេងៗមានចំនួន**៥៦**កន្លែង ដែលក្នុងនេះមានដូចជាប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក សំណង់ទីទួលសុវត្ថិភាព សាឡង់ សំណង់ស្ថានីយ៍បូមទឹក ផែបណ្តែតទឹកសហគមន៍។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

រូបភាពទី២៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោង




## ២.២. ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់លើឯកសាររបាយការណ៍សុវត្ថិភាពបរិស្ថានស្ថិតក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប**៥៣៤**គម្រោង ស្មើនឹង**៩៣%**នៃចំនួនសរុប **៥៧៤** គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន**៦៧**គម្រោង ស្មើ**៦៨%**នៃចំនួនសរុបចំនួន**៩៨**គម្រោងដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច ។

ក្រុមការងារបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសកិច្ចការពារសុវត្ថិភាពបរិស្ថានលើគម្រោងក្រុង ស្រុកបានចំនួន៤គម្រោង របស់ខេត្តពោធិ៍សាត់ និងខេត្តព្រះសីហនុ ។

ក្រុមការងារបានជួយពិនិត្យគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ដោយបានផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន នៃការអនុវត្តគម្រោងរបស់ខេត្តសៀមរាប និងខេត្តកំពង់ចាម សរុបចំនួន **១៧**គម្រោង ។

ក្រុមការងារបានជួយពិនិត្យ និងផ្តល់យោបល់លើគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់(SNC Scale-up 2014) លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន បានចំនួន **៥**គម្រោងរបស់ខេត្តបាត់ដំបង ។ ដោយឡែកគម្រោងដែលនៅសល់មួយចំនួនទៀតមន្ត្រីទីចាត់ការផែនការ និងវិនិយោគនៅថ្នាក់ក្រោមជាតិកំពុងរៀបចំនឹងផ្ញើមកបន្តបន្ទាប់នៅចុងឆ្នាំ២០១៤នេះ ។ ក្រាហ្វិចខាងក្រោមបង្ហាញចំនួនគម្រោងដែលបានពិនិត្យនិងផ្តល់យោបល់បច្ចេកទេស ។

រូបភាពទី៣៖ ក្រាហ្វិចចំនួនគម្រោង និងភាគរយដែលបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេស



### ២.៣. ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៣៖

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគនៅក្នុងខេត្តចំនួនប្រាំបួន និងចុះទៅដល់ឃុំ សង្កាត់ និងដល់ទីតាំងគម្រោង បានសរុបចំនួន១៧៨ គម្រោង ស្មើនឹង៥៨% នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន៣១០គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ ធ្វើឡើងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ ជាងនេះទៅទៀត ក្រុមការងារមិនគ្រាន់តែត្រួតពិនិត្យគម្រោងដែលមានតម្រូវការសិក្សាដីធ្លីប៉ុណ្ណោះទេ តែថែមទាំងបានពិនិត្យគម្រោងដែលមិនមានតម្រូវការសិក្សាដីធ្លីផងដែរ ដើម្បីប្រាកដថា ការអនុវត្តបានអនុលោមតាមគោលការណ៍ណែនាំដែរឬយ៉ាងណានោះ។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានបង្ហាញពីលទ្ធផលដល់នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករង និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងទីប្រឹក្សាខេត្តពាក់ព័ន្ធ ដើម្បីផ្តល់យោបល់លើចំណុចខ្វះខាតដែលជាមេរៀននិងបទពិសោធន៍សម្រាប់អនុវត្តនៅឆ្នាំក្រោយៗទៀត។ តារាងខាងក្រោមបង្ហាញពីចំនួនឯកសាររបាយការណ៍សិក្សាដីធ្លី ដែលក្រុមការងារបានត្រួតពិនិត្យ។

**រូបភាពទី៤៖ តារាងចំនួនគម្រោងសិក្សាដីធ្លី និងភាគរយដែលបានចុះត្រួតពិនិត្យ**

| ល.រ | ឈ្មោះខេត្ត | ចំនួនគម្រោងសរុប | ចំនួនគម្រោងត្រូវការសិក្សាដីធ្លី | គម្រោងត្រូវបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | បាត់ដំបង | ១១៣ | ២០ | ១៨ | ៩០% |
| ២ | ប៉ៃលិន | ៩ | ៧ | ៧ | ១០០% |
| ៣ | កណ្តាល | ១៤១ | ៦២ | ២៩ | ៤៧% |
| ៤ | កំពង់ឆ្នាំង | ៧៣ | ៤២ | ១៧ | ៤០% |
| ៥ | កំពង់ស្ពឺ | ៩៤ | ៣៤ | ១៨ | ៥២% |
| ៦ | មណ្ឌលគិរី | ២២ | ៣ | ៣ | ១០០% |
| ៧ | ក្រចេះ | ៤៦ | ២៩ | ១៩ | ៦៦% |
| ៨ | ស្វាយរៀង | ៨៦ | ៣៨ | ២៣ | ៦១% |
| ៩ | កំពង់ធំ | ៨២ | ៧៥ | ៤៤ | ៥៩% |
| **សរុប** | | **៦៦៦** | **៣១០** | **១៧៨** | **៥៨%** |

### ២.៤. ការពង្រឹងសមត្ថភាព៖

- ថ្ងៃទី១៨-២១ ខែកុម្ភៈ ឆ្នាំ២០១៤ បានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅណែនាំស្តីពីគម្រោងរាជធានី ខេត្ត នៅខេត្តកំពង់ចាម ដែលមានសមាជិកសរុបចំនួន១៣នាក់ មកពីនាយកដ្ឋានរដ្ឋបាលទូទៅ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងលេខាធិការដ្ឋាន គ.ជ.អ.ប។
- ថ្ងៃទី២៥ -២៨ ខែមិនា ឆ្នាំ២០១៤ បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត នៅខេត្តព្រះសីហនុ ដែលមានសមាជិកចូលរួមសរុបចំនួន៩២នាក់ មកពីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងរាជធានី

ខេត្តទាំង២៤ សិក្ខាសាលានេះគឺជាការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើកទីពីរសម្រេចលើចំណុចសំខាន់ៗមួយចំនួនក្នុងខ្លឹមសារសេចក្តីព្រាងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដើម្បីយកទៅអនុវត្តន៍នៅពេលខាងមុខឱ្យប្រព្រឹត្តទៅប្រកបដោយភាពរលូននៅរាជធានី ខេត្ត។

- ថ្ងៃទី១៦-១៨ ខែមិថុនា ឆ្នាំ២០១៤ បានចូលរួមបង្រៀនសាកល្បងលើសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដល់មន្ត្រីបង្គោលដែលជាមន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សរុបចំនួន២៣នាក់ ស្រី១នាក់ ។វគ្គនេះរៀបចំឡើងនៅខេត្តបាត់ដំបង ដើម្បីជួយពង្រឹងដល់មន្ត្រីបង្គោលឱ្យទទួលបាននូវគន្លឹះល្អៗសម្រាប់យកទៅបង្រៀនបន្តនៅថ្នាក់ក្រោមជាតិ។
- ថ្ងៃទី១៩-២០ ខែមិថុនា ឆ្នាំ២០១៤ បានចូលរួមបង្រៀនវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ជុំវិញបឹងទន្លេសាប នៅក្នុងខេត្តកំពង់ធំ ដែលមានសមាសភាពចូលរួមជាអ្នកជំនួយបច្ចេកទេសឃុំសង្កាត់ មន្ត្រីសម្របសម្រួលគម្រោងក្រុងស្រុក មន្ត្រីជំនួយបច្ចេកទេសខេត្ត សរុបចំនួន៦៥នាក់ ស្រី៩នាក់ ។ វគ្គនេះ រៀបចំឡើងក្នុងគោលបំណងរំលឹកដល់អ្នកអនុវត្តគម្រោងទាំងនោះបំពេញបន្ថែមនូវការខ្វះចន្លោះដែលតែងតែកើតមានជារៀងរាល់ឆ្នាំ។
- ថ្ងៃទី២៦-២៧ ខែមិថុនា ឆ្នាំ២០១៤ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០១៤ ភ្ជាប់ជាមួយនិងវគ្គរំលឹកឡើងវិញស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំសង្កាត់នៅសាលប្រជុំក្រសួងមហាផ្ទៃ ដែលមានសមាសភាពចូលរួមជា នាយកនាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពខេត្ត សរុបចំនួន៨៥ នាក់ស្រី៧នាក់។
- ថ្ងៃទី០៧-០៩ ខែកក្កដា ឆ្នាំ២០១៤ បានចូលរួមកិច្ចប្រជុំស្តីពីការអនុវត្តការត្រួតពិនិត្យការគ្រប់គ្រងសកម្មភាព និងថវិកា ឆ្នាំ២០១៤ និងលើកទិសដៅបន្ត នៅសាលប្រជុំ ក្រសួងមហាផ្ទៃ ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប ។ សមាសភាពចូលរួមជា នាយករដ្ឋបាលសាលាខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត មន្ត្រីទទួលបន្ទុកបញ្ចូល NAD ទីប្រឹក្សាហិរញ្ញវត្ថុរាជធានី ខេត្ត មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុមកពីទីចាត់ការហិរញ្ញវត្ថុ តំណាងប្រធាន អនុប្រធានក្រុមការងារនៃអនុកម្មវិធី មន្ត្រី និងទីប្រឹក្សា និងក្រុមការងារទាំងបួនអង្គភាព នៃលេខាធិការដ្ឋាន គ.ជ.អ.ប សរុបចំនួន១៧៣នាក់។
- ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងនាយករដ្ឋបាលសាលាខេត្ត ដែលអញ្ជើញមកពីខេត្តទាំង២៤ និងរាជធានីភ្នំពេញ សរុបចំនួន៧៥នាក់។កិច្ចប្រជុំផ្សព្វផ្សាយនេះរៀបចំនិងសម្របសម្រួលដោយមន្ត្រី និងទីប្រឹក្សា នៃអនុកម្មវិធីទី១ អនុកម្មវិធីទី២ និងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ដើម្បីផ្សព្វផ្សាយដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងនាយករដ្ឋបាលសាលាខេត្ត ឱ្យបានជ្រួតជ្រាបអំពីខ្លឹមសារនៃការណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត។

o ថ្ងៃទី០៤-០៩ ខែសីហា ឆ្នាំ២០១៤ បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដល់ទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាព និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត ទាំង២៤និងរាជធានីភ្នំពេញ សរុបចំនួន៨៧នាក់។ វគ្គនេះរៀបចំឡើងនៅក្នុងខេត្តកំពង់ចាម ដោយមានមន្ត្រី និងទីប្រឹក្សា នៃអនុកម្មវិធីទី១ អនុកម្មវិធីទី២ និងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ក្នុងគោលបំណងបណ្តុះបណ្តាលស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីយកទៅអនុវត្តន៍នៅថ្នាក់ក្រោមជាតិ។

**២.៥. ការគាំទ្រ និងកិច្ចសហការៈ**

- ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្តទាំងអស់ដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី ដើម្បីផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងឱ្យទាន់ពេលវេលានិងឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ។
- ក្រុមការងារបានសហការជាមួយអនុកម្មវិធីទី២ នៃអគ្គនាយកដ្ឋានរដ្ឋាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ក្នុងការរៀបចំសៀវភៅគោលការណ៍ណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដូចជា ជួយផ្តល់យោបល់ដើម្បីកែតម្រូវនូវចំណុចបច្ចេកទេសមួយចំនួននៅក្នុងផ្នែកគោលនយោបាយស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច និងជួយសម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់អំពីសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក នៅខេត្តកំពង់ចាម ព្រមទាំងបានជួយសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលសាកល្បងស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ដល់គ្រូឧទ្ទេសថ្នាក់ជាតិនៅខេត្តបាត់ដំបង។

## ៣. បញ្ហាប្រឈមនានា

- ក្នុងឆ្នាំនេះមានការសិក្សាផលប៉ះពាល់យឺតយ៉ាវរហូតដល់ពាក់កណ្តាលឆ្នាំទើបមានខេត្តមួយចំនួនបានផ្ញើឯកសារ និងរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសដែលជាហេតុបណ្តាលឱ្យមានការដេញថ្លៃយឺតយ៉ាវ។
- ខេត្តមួយចំនួនបានធ្វើការសិក្សាផលប៉ះពាល់បរិស្ថានមុនធ្វើតម្រូវការសិក្សាគម្រោង និងធ្វើផែនការគម្រោងឃុំសង្កាត់ ដែលខុសនឹងនីតិវិធីដែលមានចែងក្នុងសៀវភៅ (ភីម) ជាហេតុនាំឱ្យមានការរៀបចំឯកសារម្តងហើយម្តងទៀត ។
- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មួយចំនួនមានភាពមិនប្រក្រតី និងនៅមានភាពខ្វះចន្លោះច្រើន ដូចជា គម្រោងខ្លះត្រូវការសិក្សាដីធ្លី តែបែរជាមិនបានសិក្សាដីធ្លីទៅវិញ គម្រោងមួយចំនួនត្រូវរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី(ទូទាត់សំណង) ប៉ុន្តែ គម្រោងទាំងនោះ បែរជារៀបចំរបាយការណ៍បរិច្ចាគដីធ្លីដោយស្មគ្រ័ចិត្តទៅវិញ ឯកសារគម្រោងច្បាប់ដើមភាគច្រើនមិនបានរក្សាទុកនៅសាលាឃុំ សង្កាត់ ការចុះអង្កេតដីធ្លីមុនការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី (ប្រជុំ

លើកទី១) មិនចុះកាលបរិច្ឆេទអនុវត្តគម្រោង និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តមិនបាន កំណត់អ័ក្ស ឬកូដផ្លូវឱ្យបានច្បាស់លាស់ដែលបណ្តាលឱ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មានការ មិនសប្បាយចិត្ត និងមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ដែលជាអ្នកទទួលរងផលប៉ះពាល់ដីធ្លី និង ទ្រព្យសម្បត្តិផ្សេងៗ។

- នៅមានកង្វះខាតនូវការតាមដាន និងការគាំទ្រពីសំណាក់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និង មន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ចំពោះការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើម ភាគតិច ជាពិសេស ក្រុមប្រឹក្សាឃុំ សង្កាត់មិនសូវយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យគម្រោងរបស់ ខ្លួន ឱ្យបានដិតដល់ ដែលជាហេតុបណ្តាលឱ្យការអនុវត្តគម្រោងមិនបានត្រឹមត្រូវតាមគោលការណ៍ណែ នាំ និងលិខិតបទដ្ឋាននានារបស់លេខាធិការដ្ឋាន។
- ខ្វះកិច្ចសហការគ្នារវាងមន្ត្រីគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ទីប្រឹក្សាពាក់ព័ន្ធ និងខ្វះការតាមដាន ត្រួតពិនិត្យពីសំណាក់មន្ត្រីហេដ្ឋារចនាសម្ព័ន្ធខេត្ត ដែលបណ្តាលឱ្យការអនុវត្ត គម្រោងមូលនិធិឃុំ សង្កាត់មិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

## ៤. ការសន្និដ្ឋាន

ពិនិត្យជារួម ក្នុងឆ្នាំ២០១៤នេះ ក្រុមការងារបានអនុវត្តសកម្មភាពការងារស្របទៅតាមផែនការសកម្មភាព ដែលបានគ្រោងទុក ទាំងការត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លី ទាំងការពិនិត្យ និងផ្តល់យោបល់លើការអនុ វត្តសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ទោះបីមានការយឺតយ៉ាវ ក្នុងការសិក្សាគម្រោងទាំងនោះយ៉ាងណាក៏ដោយ។ តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លី ជួបជាមួយ អ្នកពាក់ព័ន្ធ និង ការចុះអង្កេតផ្ទាល់ ពិនិត្យឃើញថា ការរៀបចំឯកសារ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៣ ទាក់ទងទៅនឹងដីធ្លី មានលក្ខណៈល្អបង្គួរ បើប្រៀបធៀបទៅនឹងឯកសាររបាយការណ៍សុវត្ថិភាពដីធ្លី នៃ ការអនុវត្តគម្រោងឃុំ សង្កាត់ ឆ្នាំ២០១២។ ទន្ទឹមនឹងលក្ខណៈល្អបង្គួរនេះ ក្រុមការងារបានសង្កេតឃើញថា នៅមានឃុំ សង្កាត់មួយចំនួនបំពេញឯកសារគម្រោងតាមទម្រង់នានានៅមានភាពខ្វះចន្លោះ ដូចជា មិនបំពេញកាលបរិច្ឆេទបញ្ចប់ ការសិក្សាគម្រោង មិនបានបញ្ជាក់និងប្រថាប់ត្រានៅគ្រប់សន្លឹកក្នុងទម្រង់ទី២០.៥ ព្រមទាំងផ្តិតមេដៃខុសកូឡោន ក្នុងទម្រង់ទី២០.៥ និងការគូរផែនទីអង្កេតដីធ្លីមិនបានបង្ហាញក្បាលដីនីមួយៗ ដែលប៉ះពាល់ដោយសារការអនុវត្ត គម្រោង។ ជាមួយគ្នានឹងការបំពេញឯកសារខ្វះចន្លោះនេះ ខេត្តនីមួយៗជួបនូវបញ្ហាមួយចំនួន ដូចជា ខ្វះឧបករណ៍ ប្រើប្រាស់ ខ្វះមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងខ្វះកិច្ចសហការពីមន្ទីរអភិវឌ្ឍជនបទ ។ ដូចនេះ ដើម្បីពង្រឹង ការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពទាំងបី ជាពិសេស កិច្ចការពារសុវត្ថិភាពដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ ឱ្យបានឆ្លើយតបតាមគោលការណ៍ណែនាំដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែមានការប្តេជ្ញា ចិត្ត និងការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការផ្តោតជាសំខាន់លើការតាមដាន ការត្រួត ពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាកសាង និងអភិវឌ្ឍសមត្ថភាពខេត្ត ទាំងការរៀបចំទុក ដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក មន្ត្រីបច្ចេក ទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តផងដែរ។

## ៥. សំណូមពរ និងអនុសាសន៍

- ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពទាំងបី ជាពិសេស កិច្ចការពារសុវត្ថិភាពដីធ្លី នៃគម្រោងមូលនិធិឃុំ សង្កាត់ និងដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែបង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការតាមដាន ត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពង្រឹងសមត្ថភាព ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ។
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និង មន្ត្រីពាក់ព័ន្ធថ្នាក់ខេត្តត្រូវជួយពង្រឹងឱ្យមានកិច្ចសហការគ្នាល្អរវាងមន្ត្រីគាំទ្របច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ នៃទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្ត តាមរយៈការរៀបចំផែនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបីរួមគ្នា ការចុះសិក្សាគម្រោងរួមគ្នា និងការចូលរួមប្រជុំប្រចាំខែ ឬប្រជុំប្រចាំត្រីមាសរបស់កម្មវិធីវិនិយោគជាទៀងទាត់ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការសិក្សា ការរៀបចំឯកសារគម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា ព្រមទាំងបង្កើននូវការតាមដាន ត្រួតពិនិត្យពេលអនុវត្តគម្រោង និងថែទាំលទ្ធផលគម្រោងឱ្យបានជាប់ជាប្រចាំ ។
- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសទ្រឃុំសង្កាត់ត្រូវបង្កើនការចុះតាមដាន និងការត្រួតពិនិត្យលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឱ្យបានដិតដល់ ។
- ខេត្តគួរពិនិត្យលទ្ធភាពក្នុងផ្តល់ការហ្វឹកហ្វឺនបន្ថែមទៀតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំសង្កាត់មានសមត្ថភាពសមល្មមក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីឱ្យបានត្រឹមត្រូវដោយខ្លួនឯង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក ដើម្បីឱ្យពួកគេមានសមត្ថភាពក្នុងការជួយគាំទ្រឃុំ សង្កាត់ ។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៥

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥សម្រាប់ក្រុមការងារកិច្ចការពារសុវត្ថិភាព ។
- ធ្វើបច្ចុប្បន្នភាពនៃបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថាន និងបញ្ជីជនជាតិដើមភាគតិច ។
- បើកវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ។
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសារកិច្ចការពារសុវត្ថិភាពបរិស្ថាន និងឯកសារសុវត្ថិភាពជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក ។
- ចុះតាមដានវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ។
- រៀបចំកិច្ចប្រជុំប្រចាំឆមាស និងកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ ស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ ។

- ចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក ឆ្នាំ២០១៤ ។
- សម្របសម្រួលជាមួយអនុកម្មវិធីទី២ ក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលានានាដល់មន្ត្រី និងទីប្រឹក្សាពាក់ពន្ធ័នៅថ្នាក់ក្រោមជាតិ ។
- សម្របសម្រួលជាមួយការិយាល័យពាក់ព័ន្ធនៃអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី និងទីប្រឹក្សាពាក់ព័ន្ធថ្នាក់ជាតិដើម្បីរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៦ ក្នុងគោលដៅដើម្បីគាំទ្រដល់ការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប។

**រៀបចំដោយ**
**ក្រុមការងារកិច្ចការពារសុវត្ថិភាព**
**លេខាធិការដ្ឋាន គ.ជ.អ.ប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខ: [illegible]/អ.គ.គ.ក

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**សូមគោរពជូន**
**ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**តាមរយៈ:** ឯកឧត្តមអនុប្រធានប្រតិបត្តិលេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ:** របាយការណ៍សង្ខេបលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចប្រចាំឆ្នាំ២០១៤ ។

**យោង:** - សេចក្តីសម្រេចលេខ ៧៨ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប។

- ផែនការសកម្មភាពរបស់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចឆ្នាំ២០១៤

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាកិច្ចការមួយដ៏សំខាន់បំផុតដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ រួមមាន៖ ក្រសួង ស្ថាប័ននានា ក្រុមការងារ និងមន្ត្រីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការចូលរួមពីប្រជាពលរដ្ឋផងដែរ។ ក្នុងឆ្នាំ២០១៤នេះ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានខិតខំបំពេញការងារតាមផែនការសកម្មភាពរបស់ខ្លួន ដោយបានយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ រហូតទទួលបានលទ្ធផលជាចម្បងៗគួរឲ្យកត់សំគាល់ រួមមានដូចខាងក្រោមនេះ ៖

១- បានចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីរបស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៣ នៅទីចាត់ការផែនការនិងវិនិយោគខេត្ត និងនៅសាលាឃុំ សង្កាត់ ក្នុងខេត្តចំនួន០៩ គឺខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តស្វាយរៀង និងខេត្តកំពង់ធំ សរុបបានចំនួន**១៧៨**គម្រោង ស្មើនឹង**៥៨**% នៃគម្រោងមូលនិធិឃុំ សង្កាត់សរុបចំនួន **៦៦៦**គម្រោង ដែលត្រូវការសិក្សាដីធ្លីចំនួន**៣១០**គម្រោងតែប៉ុណ្ណោះ។

២- បានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចខេត្ត រៀបចំបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តឆ្នាំ២០១៤ មានសរុបចំនួន **១.៦៦៥** គម្រោង នៃឃុំ សង្កាត់ចំនួន**១.៥៣៧**

ក្នុងនោះរួមមាន៖ តម្រូវការសិក្សាបរិស្ថានចំនួន**៦៧៥**គម្រោង តម្រូវការសិក្សាដីធ្លីចំនួន **៦៤៨** គម្រោង និងតម្រូវការសិក្សាកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច ចំនួន**៩៨**គម្រោង។ គម្រោងមូលនិធិឃុំសង្កាត់ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន មានចំនួនសរុប **៥៧៤**គម្រោង និងគម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីជនជាតិដើមភាគតិច មានចំនួនសរុប **៩៨**គម្រោង។

**៣**-បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសឯកសាររបាយការណ៍សុវត្ថិភាពបរិស្ថាននៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៤ ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន សរុបចំនួន**៥៣៤**គម្រោង ស្មើនឹង **៩៣**ភាគរយ នៃគម្រោងសរុបចំនួន **៥៧៤**គម្រោង។

**៤**- បានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើវិធានការពារជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច សរុបចំនួន **៦៧**គម្រោង ស្មើនឹង**៦៨**ភាគរយ នៃគម្រោងសរុបចំនួន**៩៨**គម្រោង។

**៥**- បានជួយដល់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ដោយបានផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន នៃការអនុវត្តគម្រោងរបស់ខេត្តសៀមរាប និងខេត្តកំពង់ចាម សរុបចំនួន**១៧**គម្រោង ក្នុងនោះឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានរបស់ខេត្តសៀមរាប ចំនួន**០៧**គម្រោង និងខេត្តកំពង់ចាម ចំនួន**១០**គម្រោង ព្រមទាំងបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសសុវត្ថិភាពបរិស្ថានលើឯកសារគម្រោងឃុំ សង្កាត់ ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន ឆ្នាំ២០១៤ ( SNC Scale up 2014 ) នៅក្នុងខេត្តបាត់ដំបងបានចំនួន **០៥**គម្រោងផងដែរ។

តាមរយៈការពិនិត្យឯកសារ ការចុះត្រួតពិនិត្យ និងអនុវត្តការងារជាក់ស្តែង ក្រុមការងារពិនិត្យឃើញនូវបញ្ហាប្រឈមមួយចំនួន រួមមានដូចខាងក្រោម៖

**១**-ការសិក្សាផលប៉ះពាល់រហូតដល់ពាក់កណ្តាលឆ្នាំទើបមានខេត្តមួយចំនួនបានផ្ញើឯកសារនិងរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស ដែលជាហេតុបណ្តាលឲ្យមានយឺតយ៉ាវដល់ការដេញថ្លៃផងដែរ។

**២**- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មួយចំនួនមានភាពមិនប្រក្រតី និងនៅមានភាពខ្វះចន្លោះច្រើន ដូចជា គម្រោងខ្លះត្រូវការសិក្សាដីធ្លី តែបែរជាមិនបានសិក្សាដីធ្លីទៅវិញ គម្រោងមួយចំនួនត្រូវរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី(ទូទាត់សំណង) ប៉ុន្តែ គម្រោងទាំងនោះ បែរជារៀបចំរបាយ-ការណ៍បរិច្ចាគដីធ្លីដោយស្មគ្រ័ចិត្តទៅវិញ ឯកសារគម្រោងច្បាប់ដើមភាគច្រើនមិនបានរក្សាទុកនៅសាលាឃុំ សង្កាត់ ការចុះអង្កេតដីធ្លីមុនការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី(ប្រជុំលើកទី១) មិនចុះកាលបរិច្ឆេទអនុវត្តគម្រោង និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តមិនបានកំណត់អ័ក្ស ឬកូដផ្លូវឲ្យបានច្បាស់លាស់ដែលបណ្តាលឲ្យការអនុវត្តគម្រោងមូលនិធិឃុំ

សង្កាត់មានការមិនសប្បាយចិត្ត និងមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ដែលជាអ្នកទទួលរងផលប៉ះពាល់ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗ។

៣- នៅមានកង្វះខាតនូវការតាមដាន និងគាំទ្រពីសំណាក់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ចំពោះការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាពិសេស ក្រុមប្រឹក្សាឃុំ សង្កាត់ មិនសូវយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យគម្រោងរបស់ខ្លួនឲ្យបានដិតដល់ ដែលជាហេតុបណ្តាលឲ្យការអនុវត្តគម្រោងមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

៤- នៅមានកង្វះខាតនូវកិច្ចសហការគ្នារវាងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពាក់ព័ន្ធនានាថ្នាក់ខេត្តដែលជាហេតុបណ្តាលឲ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារនូវការយកចិត្តទុកដាក់ពីមន្ត្រីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ និងការបង្កើនសមត្ថភាពមន្ត្រីពាក់ព័ន្ធនានា តាមរយៈការបណ្តុះបណ្តាល ការប្រជុំ ការចុះពិនិត្យឯកសារ និងការចុះពិនិត្យដល់ទីតាំងគម្រោង ព្រមទាំងការពង្រឹង និងជំរុញការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ ក្នុងគោលដៅ ដើម្បីធានាឲ្យបាននូវការឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

សូមភ្ជាប់មកជាមួយនូវរបាយការណ៍រីកចំរើនប្រចាំឆ្នាំ២០១៤ ចំនួន០១ច្បាប់ តារាងឧបសម្ព័ន្ធ **៧.១** ឧបសម្ព័ន្ធ**៧.២** ឧបសម្ព័ន្ធ**៧.៣** និងឧបសម្ព័ន្ធ**៧.៤**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

បានឃើញ និងសូមគោរពជូនឯកឧត្តម
មេត្តាជ្រាបជាសេចក្តីរាយការណ៍។
ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី

**នី គីមសាន**

ប្រធានក្រុមការងារ

**ខោល យុទ្ធលី**

បានឃើញ

**ចិរ៉ាន់ ចំរើន**

19/12/2014

# ឧបសម្ព័ន្ធ៧.១ បញ្ជីសង្ខេបគម្រោងមូលនិធិឃុំសង្កាត់ទាំង២៣ខេត្តក្នុងឆ្នាំ២០១៤

## ខេត្តទាំង២៣

| លេខកូដ | ឈ្មោះខេត្ត/ស្រុក | ួនឃុំសង្ក | ចំនួនគម្រោង | ចំនួនគម្រោងលើកឡើង ២០១៤ សម្រាប់ | | | | | | | តំរូវការសិក្សាសុវត្ថិភាព | | | ងតំបន់ឃ្លាំ | ឈ្មោះមន្ត្រីទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ផ្លូវ | ស្ពាន | ធារាសាស្ត្រ | អណ្តូង | សាលា | បង្គន់ | ផ្សេងៗ | បរិស្ថាន | ដីធ្លី | ជនជាតិ | | |
| 4 | **កំពង់ឆ្នាំង** | | | | | | | | | | | | | | |
| 401 | បរិបូណ៌ | 11 | 11 | 9 | 0 | 0 | 0 | 1 | 0 | 1 | 3 | 8 | 0 | 2 | ហង្ស ពិសី និងឡេង សំអេត |
| 402 | ជលគិរី | 5 | 6 | 4 | 0 | 1 | 0 | 0 | 0 | 1 | 6 | 6 | 0 | 5 | ហង្ស ពិសី និងឡេង សំអេត |
| 403 | ក្រុង កំពង់ឆ្នាំង | 4 | 4 | 4 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | ហង្ស ពិសី និងឡេង សំអេត |
| 404 | កំពង់លែង | 9 | 7 | 7 | 0 | 0 | 0 | 0 | 0 | 0 | 2 | 2 | 0 | 6 | ហង្ស ពិសី និងឡេង សំអេត |
| 405 | កំពង់ត្រឡាច | 10 | 10 | 10 | 0 | 0 | 0 | 0 | 0 | 0 | 3 | 8 | 0 | 3 | ហង្ស ពិសី និងឡេង សំអេត |
| 406 | រលាប្អៀរ | 13 | 13 | 13 | 0 | 0 | 0 | 0 | 0 | 0 | 4 | 11 | 0 | 4 | ហង្ស ពិសី និងឡេង សំអេត |
| 407 | សាមគ្គីមានជ័យ | 9 | 11 | 8 | 0 | 1 | 2 | 0 | 0 | 0 | 0 | 7 | 0 | 0 | ហង្ស ពិសី និងឡេង សំអេត |
| 408 | ទឹកផុស | 8 | 8 | 7 | 0 | 1 | 0 | 0 | 0 | 0 | 4 | 7 | 0 | 4 | ហង្ស ពិសី និងឡេង សំអេត |
| **សរុបរង** | 8 | **69** | **70** | **62** | **0** | **3** | **2** | **1** | **0** | **2** | **23** | **50** | **0** | **24** | |
| 5 | **កំពង់ស្ពឺ** | | | | | | | | | | | | | | |
| 502 | ក្រុង ច្បារមន | 15 | 16 | 15 | 0 | 0 | 0 | 0 | 0 | 1 | 0 | 13 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 501 | បរសេដ្ឋ | 5 | 5 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 503 | គងពិសី | 13 | 14 | 12 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 504 | ឱរ៉ាល់ | 5 | 6 | 6 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | 3 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 505 | ឧត្តុង្គ | 15 | 16 | 12 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 506 | ភ្នំស្រួច | 12 | 14 | 6 | 0 | 4 | 2 | 1 | 0 | 1 | 10 | 8 | 0 | 9 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 507 | សំរោងទង | 15 | 16 | 13 | 2 | 0 | 1 | 0 | 0 | 0 | 6 | 0 | 0 | 6 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| 508 | ថ្ពង | 7 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 1 | 3 | 0 | 1 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនធាង |
| **សរុបរង** | 8 | **87** | **95** | **77** | **3** | **7** | **4** | **1** | **0** | **2** | **19** | **24** | **0** | **19** | |
| 8 | **កណ្តាល** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 801 | កណ្តាលស្ទឹង | 18 | 20 | 16 | 0 | 4 | 0 | 0 | 0 | 0 | 0 | 8 | 0 | 0 | តេង រិទ្ធី |
| 802 | កៀនស្វាយ | 8 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 2 | វ៉ាត រិទ្ធ និងទ្រី ប៊ុនហ៊ាង |
| 803 | ខ្សាច់កណ្តាល | 18 | 17 | 17 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | គៀង សុខណាត |
| 804 | កោះធំ | 11 | 11 | 9 | 1 | 1 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ហេង ង៉នលាង |
| 805 | លើកដែក | 7 | 7 | 4 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ម៉ុល ម៉ាលី |
| 806 | ល្វាឯម | 15 | 19 | 17 | 0 | 2 | 0 | 0 | 0 | 0 | 0 | 11 | 0 | 0 | លុន ឌុម និងទ្រី ប៊ុនហ៊ាង |
| 807 | មុខកំពូល | 7 | 7 | 7 | 0 | 0 | 0 | 0 | 0 | 0 | 2 | 1 | 0 | 2 | ឃឹម ផ្កា និងទ្រី ប៊ុនហ៊ាង |
| 808 | អង្គស្នួល | 10 | 11 | 10 | 0 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | មិន ភី |
| 809 | ពញាឮ | 11 | 11 | 11 | 0 | 0 | 0 | 0 | 0 | 0 | 1 | 6 | 0 | 0 | ចេវ ឈី |
| 810 | ស្អាង | 16 | 21 | 18 | 0 | 3 | 0 | 0 | 0 | 0 | 0 | 13 | 0 | 0 | ឃុត ផល្លា |
| 811 | ក្រុង តាខ្មៅ | 6 | 6 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ប៊ិន រមនី |
| | **11** | **127** | **138** | **123** | **1** | **14** | **0** | **0** | **0** | **0** | **5** | **53** | **0** | **4** | |
| **14** | **ព្រៃវែង** | | | | | | | | | | | | | | |
| 1401 | បាភ្នំ | 9 | 10 | 8 | 0 | 1 | 0 | 0 | 0 | 1 | 0 | 8 | 0 | 0 | ឈុន ណាត |
| 1402 | កំចាយមារ | 8 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1403 | កំពង់ត្របែក | 13 | 13 | 11 | 0 | 2 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ឈុន ណាត |
| 1404 | កញ្ជៀច | 8 | 9 | 6 | 0 | 2 | 0 | 1 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1405 | មេសាង | 8 | 8 | 7 | 0 | 0 | 0 | 1 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1406 | ពាមជរ | 10 | 10 | 7 | 0 | 3 | 0 | 0 | 0 | 0 | 3 | 4 | 0 | 3 | ឈុន ណាត |
| 1407 | ពាមរក៍ | 8 | 9 | 7 | 0 | 0 | 0 | 0 | 0 | 2 | 0 | 4 | 0 | 0 | សាង សានហ៊ី   និងឈុន ណាត |
| 1408 | ពារាំង | 9 | 12 | 10 | 0 | 2 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1409 | ព្រះស្តេច | 11 | 11 | 7 | 0 | 3 | 0 | 0 | 0 | 1 | 0 | 3 | 0 | 0 | ឈុន ណាត |
| 1410 | ក្រុង ព្រៃវែង | 3 | 4 | 2 | 0 | 2 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1411 | ពោធិ៍រៀង | 7 | 7 | 6 | 0 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1412 | ស៊ីធរកណ្តាល | 11 | 12 | 12 | 0 | 0 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ឈុន ណាត |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1413 | ស្វាយអន្ទរ | 11 | 11 | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ឈុន ណាត |
| **សរុបរង** | 13 | **116** | **124** | **102** | **0** | **16** | **0** | **2** | **0** | **4** | **3** | **46** | **0** | **3** | |
| **20** | **ស្វាយរៀង** | | | | | | | | | | | | | | |
| 2001 | ចន្ទ្រា | 6 | 6 | 5 | 0 | 1 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2002 | កំពង់រោទិ៍ | 11 | 11 | 7 | 0 | 4 | 0 | 0 | 0 | 0 | 0 | 5 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2003 | រំដួល | 10 | 11 | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2004 | រមាសហែក | 16 | 16 | 16 | 0 | 0 | 0 | 0 | 0 | 0 | 2 | 4 | 0 | 2 | ព្រុំ សោភណ្ឌ័ |
| 2005 | ស្វាយជ្រំ | 16 | 17 | 14 | 0 | 1 | 0 | 0 | 0 | 1 | 1 | 8 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2006 | ក្រុង ស្វាយរៀង | 7 | 9 | 4 | 0 | 0 | 0 | 0 | 0 | 5 | 0 | 3 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2007 | ស្វាយទាប | 9 | 9 | 9 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| 2008 | ក្រុង បាវិត | 5 | 5 | 4 | 0 | 0 | 0 | 0 | 0 | 1 | 0 | 3 | 0 | 0 | ព្រុំ សោភណ្ឌ័ |
| **សរុបរង** | 8 | **80** | **84** | **70** | **0** | **6** | **0** | **0** | **0** | **7** | **3** | **36** | **0** | **2** | |
| **21** | **តាកែវ** | | | | | | | | | | | | | | |
| 2101 | អង្គរបុរី | 6 | 7 | 6 | 0 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2102 | បាទី | 15 | 18 | 10 | 0 | 6 | 2 | 0 | 0 | 0 | 4 | 10 | 0 | 4 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2103 | បុរីជលសា | 5 | 5 | 3 | 0 | 1 | 0 | 1 | 0 | 0 | 0 | 3 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2104 | គិរីវង់ | 12 | 13 | 6 | 0 | 6 | 0 | 0 | 0 | 1 | 6 | 11 | 0 | 6 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2105 | កោះអណ្ដែត | 6 | 5 | 4 | 0 | 1 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2106 | ព្រៃកប្បាស | 13 | 14 | 5 | 1 | 8 | 0 | 0 | 0 | 0 | 0 | 8 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2107 | សំរោង | 11 | 12 | 9 | 0 | 3 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2108 | ក្រុង ដូនកែវ | 3 | 5 | 3 | 0 | 1 | 0 | 0 | 0 | 1 | 0 | 5 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2109 | ត្រាំកក់ | 15 | 15 | 14 | 0 | 1 | 0 | 0 | 0 | 0 | 2 | 13 | 0 | 2 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| 2110 | ទ្រាំង | 14 | 14 | 9 | 0 | 5 | 0 | 0 | 0 | 0 | 0 | 10 | 0 | 0 | អ៊ុន ប៊ុន និង ចន្ទរដ្ឋា |
| **សរុបរង** | **10** | **100** | **108** | **69** | **1** | **33** | **2** | **1** | **0** | **2** | **12** | **72** | **0** | **12** | |
| **15** | **ពោធិ៍សាត់** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1501 | បាកាន | 10 | 12 | 9 | 1 | 1 | 0 | 0 | 0 | 0 | 7 | 4 | 0 | 8 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| 1502 | កណ្ដៀង | 9 | 11 | 8 | 0 | 0 | 0 | 1 | 0 | 2 | 9 | 6 | 0 | 9 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| 1503 | ក្រគរ | 11 | 12 | 10 | 1 | 0 | 0 | 0 | 0 | 1 | 9 | 3 | 0 | 8 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| 1504 | ភ្នំក្រវាញ | 7 | 10 | 9 | 1 | 0 | 0 | 0 | 0 | 0 | 8 | 3 | 1 | 7 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| 1505 | ក្រុង ពោធិ៍សាត់ | 7 | 14 | 10 | 2 | 0 | 0 | 0 | 0 | 2 | 2 | 7 | 0 | 1 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| 1506 | វាលវែង | 5 | 5 | 5 | 0 | 0 | 0 | 0 | 0 | 0 | 5 | 5 | 1 | 5 | វង់ វឿន ឡោន ផល្លា និងប៉ែន រិទ្ធី |
| **សរុបខេ** | 6 | **49** | **64** | **51** | **5** | **1** | **0** | **1** | **0** | **5** | **40** | **28** | **2** | **38** | |
| 2 | **បាត់ដំបង** | | | | | | | | | | | | | | |
| 201 | បាណន់ | 8 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 3 | 3 | 0 | 0 | កៅ ជន និង ជួ សាន |
| 202 | ថ្មគោល | 10 | 12 | 9 | 0 | 3 | 0 | 0 | 0 | 0 | 7 | 0 | 0 | 5 | កៅ ជន និង ជួ សាន |
| 203 | ក្រុង បាត់ដំបង | 10 | 11 | 9 | 0 | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | កៅ ជន និង ជួ សាន |
| 204 | បវេល | 8 | 8 | 7 | 0 | 1 | 0 | 0 | 0 | 0 | 2 | 1 | 0 | 2 | កៅ ជន និង ជួ សាន |
| 205 | ឯកភ្នំ | 7 | 7 | 5 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | 6 | កៅ ជន និង ជួ សាន |
| 206 | មោងឫស្សី | 9 | 9 | 8 | 0 | 1 | 0 | 0 | 0 | 0 | 4 | 0 | 0 | 4 | កៅ ជន និង ជួ សាន |
| 207 | រតនមណ្ឌល | 5 | 7 | 6 | 0 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 1 | កៅ ជន និង ជួ សាន |
| 208 | សង្កែ | 10 | 11 | 9 | 0 | 2 | 0 | 0 | 0 | 0 | 5 | 0 | 0 | 5 | កៅ ជន និង ជួ សាន |
| 209 | សំឡូត | 7 | 7 | 6 | 0 | 0 | 0 | 0 | 0 | 1 | 6 | 1 | 1 | 6 | កៅ ជន និង ជួ សាន |
| 210 | សំពៅលូន | 6 | 7 | 5 | 0 | 0 | 0 | 0 | 0 | 2 | 7 | 1 | 0 | 6 | កៅ ជន និង ជួ សាន |
| 211 | ភ្នំព្រឹក | 5 | 6 | 6 | 0 | 0 | 0 | 0 | 0 | 0 | 6 | 1 | 0 | 5 | កៅ ជន និង ជួ សាន |
| 212 | កំរៀង | 6 | 6 | 5 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | 6 | កៅ ជន និង ជួ សាន |
| 213 | គាស់ក្រឡ | 6 | 6 | 5 | 0 | 0 | 1 | 0 | 0 | 0 | 4 | 3 | 0 | 1 | កៅ ជន និង ជួ សាន |
| 214 | រុក្ខគិរី | 5 | 6 | 3 | 0 | 3 | 0 | 0 | 0 | 0 | 3 | 2 | 0 | 0 | កៅ ជន និង ជួ សាន |
